# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៨១៩ព្ររ.៣.១០១-៩៧

## <u>សារាចរ</u>

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## <u>ជម្រាបមក</u>

### លោកព្រះរាជអាជ្ញាអមតុលាការខេត្តកំពង់ឆ្នាំង

<u>សូមជ្រាប។</u>

**<u>កម្មវត្ថុ:</u>** ស្តីពីនគរបាលស្រុកកំពង់ឆ្នាំង-ខេត្តកំពង់ឆ្នាំង ធ្វើទារុណកម្មលើជនជាប់ចោទបន្តទៀត ។
**<u>យោង:</u>** លិខិតលេខ ២២៦ អាដហុក ចុះថ្ងៃទី៣០-០៦-៩៧ របស់សមាគមអាដហុក ។

ខ្ញុំសូមជម្រាបលោកថា ក្រសួងបានទទួលលិខិតដូចមានចែងនិងយោងខាងលើបានបញ្ជាក់ថានគរបាលស្រុកកំពង់ឆ្នាំងឈ្មោះ......ឋានៈអនុសេនីទោនិងឈ្មោះ.....ជាអធិការនគរបាលស្រុកកំពង់ឆ្នាំងបានធ្វើទារុណកម្មលើឈ្មោះ......ដែលជាប់ចោទពីបទប្លន់ម៉ូតូកាលពីថ្ងៃទី២៣-០៣-៩៧ យ៉ាងព្រៃផ្សៃ ។

១-តើករណីនេះលោកបានទទួលសំណុំរឿងហើយឬនៅ ? បើបានទទួលហើយ តើលោកចាត់ការសំណុំរឿងនេះយ៉ាងណាហើយ ?

២-តើលោកអធិការនគរបាលស្រុកកំពង់ឆ្នាំង បានប្រព្រឹត្តនូវអំពើវាយដំលើជនជាប់ចោទឬទេ? បើលោកអធិការបានធ្វើអំពើវាយដំដល់ជនជាប់ចោទមែន សូមលោកធ្វើលិខិតណែនាំជាលាយលក្ខ័អក្សរពន្យល់អំពីច្បាប់ឱ្យនគរបាលបានយល់ហើយកុំឱ្យមានការខុសឆ្គងបន្តទៀត ។ ក្រោយពីធ្វើលិខិតពន្យល់ណែនាំនេះជាលាយល័ក្ខអក្សររួចហើយ បើនគរបាលនៅតែប្រព្រឹត្តអំពើធ្វើទារុណកម្មដល់ជនល្មើសបន្តទៀតនោះ ព្រះរាជអាជ្ញាត្រូវតែអនុវត្តច្បាប់នៅលើនគរបាលរូបនោះឱ្យតឹងរ៉ឹងតាមច្បាប់ដែលបានកំណត់តទៅ ។

អាស្រ័យហេតុនេះសូមលោករាយការណ៍អំពីចំណាត់ការរឿងក្តីនេះមកក្រសួងយុត្តិធម៌ជាបន្ទាន់ ដើម្បីក្រសួងមានលទ្ធភាពឆ្លើយតបទៅសមាគមន៍អាដហុកវិញ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្នួន**

<u>ចម្លងជូន</u>

-ក្រសួងមហាផ្ទៃ
-ស្នងការនគរបាលខេត្ត.ក្រុង
-ព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង
“ ដើម្បីជ្រាប”